ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

# សេចក្តីប្រកាសព័ត៌មាន

យោងស្មារតីនៃកិច្ចប្រជុំរវាងគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ និងក្រសួងការងារថៃ នាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ គណៈកម្មការសូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ ដែលមិនមានឯកសារ ឬដែលធ្លាប់ជាពលករស្របច្បាប់ ប៉ុន្តែបានផ្លាស់ប្តូរ ឬមិនបានបំពេញនីតិវិធីនានារបស់ភាគីថៃ ហើយក្លាយទៅជាពលករមិនស្របច្បាប់ជ្រាបថា យោងតាមសំណូមពររបស់រាជរដ្ឋាភិបាលកម្ពុជា និងនិយោជកថៃ រដ្ឋាភិបាលថៃនឹងសម្រួលឱ្យមានយន្តការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាទាំងអស់ ទៅតាមដំណាក់កាល និងនីតិវិធីដូចខាងក្រោម៖

<u>ដំណាក់កាលទី១</u>៖ ចាប់ពីថ្ងៃទី២៤ ខែកក្កដា ដល់ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ គឺជាដំណាក់កាលសម្រាប់និយោជកថៃទៅចុះឈ្មោះពលករកម្ពុជាមិនស្របច្បាប់ ដែលកំពុងធ្វើការនៅក្នុងរោងចក្រសហគ្រាសរបស់ខ្លួន ជាមួយមន្ត្រីក្រសួងការងារថៃ នៅការិយាល័យស្រង់ទិន្នន័យពលករបរទេស ទាំង៩៧ការិយាល័យ។

<u>ដំណាក់កាលទី២</u>៖ ចាប់ពីថ្ងៃទី០៨ ខែសីហា ដល់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ គឺជាដំណាក់កាលសម្រាប់បងប្អូនពលករកម្ពុជាទៅបង្ហាញខ្លួននៅការិយាល័យ ទាំង៩៧កន្លែងនោះ។

<u>ដំណាក់កាលទី៣</u>៖ ចាប់ពីថ្ងៃទី០៩ ខែកញ្ញា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ គឺជាដំណាក់កាល ដែលបងប្អូនពលករកម្ពុជាត្រូវធ្វើការបញ្ជាក់អត្តសញ្ញាណ ស្នើសុំ Stay Permit និង Work Permit ពីគណៈកម្មការផ្តល់ភាពស្របច្បាប់ មន្ត្រីអន្តោប្រវេសន៍ថៃ និងមន្ត្រីក្រសួងការងារថៃ។ ក្នុងដំណាក់កាលនេះបងប្អូនពលករមិនត្រូវផ្លាស់ប្តូរនិយោជក ឬទីកន្លែងធ្វើការ ឬឈប់ដោយគ្មានការអនុញ្ញាតពីនិយោជក និងក្រសួងការងារថៃនោះឡើយ។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន និងរួសរាន់ពន្យល់ថៅកែរបស់ខ្លួនឱ្យមកចុះឈ្មោះនៅការិយាល័យស្រង់ទិន្នន័យពលករបរទេស ទៅតាមដំណាក់កាល និងនីតិវិធីខាងលើ ដើម្បីបងប្អូនប្រែខ្លួនពីពលករមិនស្របច្បាប់ ទៅជាស្របច្បាប់ និងទទួលបានអត្ថប្រយោជន៍ស្របច្បាប់ជាច្រើនផ្សេងទៀត។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ +៦៦ ៨៦ ៧៩៩ ៩៩៥៧, +៦៦ ៩៤ ០៩២ ៥៩០៥, +៦៦ ៨២ ៧៧៧ ៧២១៥, +៦៦ ២ ៩៥៧ ៥៨៥១។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៧